# ការសម្ភាសរបស់លោកយាយ ពេជ្រ សុខកាន

**ក៖ អ្នកសម្ភាសឈ្មោះ ឡេង ភក្តី** **ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ ពេជ្រ សុខកាន**

ក៖ អូខេ! ឥឡូវខ្ញុំចាប់ផ្តើមសម្ភាសហើយណា៎! អញ្ចឹងមានសាកលវិទ្យាល័យនៅ សហរដ្ឋអាមេរិចមួយគាត់ចង់ដឹង... អឺ... ពីប្រវត្តិខ្លះៗទាក់ទងនឹងលោកយាយកាល ពីក្មេង។ តើរស់នៅយ៉ាងម្តេច? តើធំឡើង...

ខ៖ ចា៎ស!

ក៖ ...រស់នៅយ៉ាងម៉េច? តើកាលផ្លាស់ប្តូររបបរបស់សង្គមវាយ៉ាងម៉េច? តើមានអ្វី ខុសគ្នាខ្លះ? ហើយអញ្ចឹងខ្ញុំសូមសួរសំណួរទៅលោកយាយខ្លះៗណា៎។

ខ៖ ចា៎ស!

ក៖ ហើយឥឡូវខ្ញុំនឹងចាប់ផ្តើមពីសំនួរទីមួយទៅ ថាតើលោកយាយមានឈ្មោះ ពេញយ៉ាងដូចម្តេ៉ច? អីដែរ?

ខ៖ ឈ្មោះ ពេជ្រ សុខកាន។

ក៖ ឈ្មោះ ពេជ្រ សុខកាន ណា៎!

ខ៖ ចា៎ស!

ក៖ ហើយមានឈ្មោះអី គេហៅក្រៅទៀតនោះ?

ខ៖ អត់ផង!

ក៖ អញ្ចឹងណា៎! ហើយអញ្ចេះ កាលពីលោកយាយនៅក្មេងណា៎ បានចូលរៀនថ្នាក់ ទីប៉ុន្មានដែ?

ខ៖ អត់បានរៀនផង! រៀនអត់ចេះ។

ក៖ មែនថាឪពុកម្តាយមិនឲ្យរៀនទេ?

ខ៖ មែនថាឪពុកម្តាយមិនឲ្យទៅរៀនទេ ព្រោះយើងរៀនវាមិនចូល។

ក៖ អញ្ចឹងណាំ!

ខ៖ ចាំស!

ក៖ អញ្ចឹងបោះបង់ការៀនសូត្រតាំងពីថ្នាក់ទីមួយទៅ។

ខ៖ បានរៀនតែថ្នាក់ទីមួយ ក៏បានឈប់រៀនទៅ។

ក៖ ហើយអញ្ចឹងអត់ចេះសរសេរ អត់ចេះអានអីទេហ្វី?

ខ៖ អត់ចេះផង!

ក៖ ភាសាខ្មែរអត់ចេះដែរចុះ! ក្រៅពីភាសាខ្មែរចេះភាសាអីទៀតទេ?

ខ៖ អត់ចេះអីទៀតផង។

ក៖ កាលពីមុនថាចិនហាំ?

ខ៖ ចេះតែចិនមួយមុខហ្នឹង។

ក៖ អញ្ចឹងចេះចិន និងចេះខ្មែរណាំ! ហើយចុះលោកយាយ គឺថាស្រុកកំណើតនៅឯ ណា?

ខ៖ ស្រុកកំណើតនៅសៀមរាប។

ក៖ នៅសៀមរាបហ្នំ?

ខ៖ នៅសៀមរាប។

ក៖ នៅភូមិអី? ឃុំអី? មានចាំទេ?

ខ៖ ចាំតើ! នៅភូមិគក់ត្រាច់។

ក៖ ភូមិគក់ត្រាច់! ឃុំ?

ខ៖ ឃុំគក់ត្រាច់ ភូមិគក់ត្រាច់ម៉ង!

ក៖ ស្រុក?

ខ៖ ស្រុកសៀមរាបហ្នឹង។

ក៖ ស្រុកសៀមរាប ខេត្តសៀមរាបម៉ង?

ខ៖ ចាំស!

ក៖ យើងចុះយាយមានអាយុប៉ុន្មានហើយ?

ខ៖ ៧៨!

ក៖ ៧៨ ណាំ!

ខ៖ ចាស់!

ក៖ ហើយឥឡូវខ្ញុំសួរថា នៅពេលដែលរៀបការនៅអាយុប៉ុន្មានដែរ?

ខ៖ រៀបការនៅអាយុ ២៩។

ក៖ ២៩ ឆ្នាំណាំ!

ខ៖ ចាំស នៅ ២៩ ឆ្នាំ!

ក៖ ហើយកាលនោះ ឪពុកម្ដាយជាអ្នករៀបចំឲ្យ ឬក៏យើងជួបគ្នាជាមួយតា?

ខ៖ ឪពុកម្ដាយជាអ្នករៀបចំឲ្យ។ ឪពុកម្ដាយចិញ្ចឹម។ ឪពុកម្ដាយចិនរៀបការឲ្យ។

ក៖ ឪពុកម្ដាយចិន! ឪពុកម្ដាយខ្មែរម៉េចដែរ? មើលជួយរៀបរាប់មើល?

ខ៖ ថាចិនគេសុំយកមកចិញ្ចឹមតាំងពីតូច។ ហើយរស់នៅជាមួយ អញ្ចឹងគេរៀបការ ឲ្យតាម៉ង ហ្នឹង។

ក៖ អូ! អញ្ចឹងហ៎! មិនមែនឪពុកម្ដាយបង្កើតទេ?

ខ៖ មិនមែនឪពុកម្ដាយបង្កើតទេ?

ក៖ រៀបការជាមួយតាហ្នឹងណា៎។

ខ៖ ចា៎ស!

ក៖ ហើយចុះពេលថ្ងៃការបានជួបជាមួយតា ឬបានជួបតាកាលពីមុនថ្ងៃការ?

ខ៖ បានជួបតានៅថ្ងៃការតែម្ដង។

ក៖ បានជួបតានៅថ្ងៃការតែម្ដងណា៎!

ខ៖ ចា៎ស!

ក៖ ហើយចុះដល់ពេលជួបនៅថ្ងៃការអញ្ចឹងទៅ មានអារម្មណ៍ម៉េចដែរទៅ? មនុស្ស មិនដែលជួបគ្នា ស្គាល់គ្នា ប៉ុន្តែមកការតែម៉ង?

ខ៖ អា៎! ឪពុកម្ដាយពេញចិត្ត ហើយរៀបការយើងឲ្យគាត់តែម្ដងទៅ។

ក៖ អញ្ចឹងណា៎?

ខ៖ ចា៎ស!

ក៖ តែពេលហ្នឹងមានភ័យខ្លាចអីដែរទេ?

ខ៖ ភ័យតើ! ភ័យខ្លាចតែមិនដឹងធ្វើម៉េច បើវាត្រូវតែអញ្ចឹងហើយ។

ក៖ អញ្ចឹងណា៎!

ខ៖ ចា៎ស!

ក៖ ហើយចុះពេលនោះ គេឲ្យថ្លៃបណ្ដាការអីគេដែរ?

ខ៖ ឲ្យបានមួយតម្លឹង។

ក៖ មាសមួយតម្លឹងហ្ន៎?

ខ៖ មាសមួយតម្លឹង!

ក៖ ហើយចុះយាយមានបងប្អូនប៉ុន្មាននាក់ដែរ? ហើយយាយជាកូនទីប៉ុន្មាន?

ខ៖ ខ្ញុំកូនទី ៦ ហ្នំ!

ក៖ ចុះបងប្អូនទាំងអស់ប៉ុន្មាននាក់?

ខ៖ ១២នាក់

ក៖ អូ! ច្រើនណាស់ហំ។

ខ៖ ច្រើនណាស់។

ក៖ ឥឡូវជួយរៀបរាប់ឈ្មោះ ហើយមានចាំទេថាគាត់ធ្វើអីគេ?

ខ៖ ថីមិនចាំ! សុទ្ធតែធ្វើស្រែចម្ការហ្នឹង។

ក៖ អញ្ចឹងរៀបរាប់ឈ្មោះមក។

ខ៖ បងគេជា, ជួប, ជុំ, មកដែរតាមាច, មកខ្ញុំ, មីគី, កាព្រាង, កាព្រម, វាភ្លោះទាំង អស់១២នាក់ទាំងអស់។

ក៖ អូខេ! ឥឡូវសព្វថ្ងៃគាត់នៅរស់ទាំងអស់គ្នាទេ?

ខ៖ អត់ដឹងផង! គាត់ស្រុកសៀមរាបណោះ។

ក៖ អញ្ចឹងយាយមកតែឯង អត់ដឹងថាពួកគាត់យ៉ាងម៉េចទេ?

ខ៖ បែកតែឯងមក! រស់នៅជាមួយចិន។ ចិនគេសុំយកធ្វើកូន។

ក៖ អញ្ចឹងចេញមករហូត លែងមកស្រុកវិញម៉ង។

ខ៖ ទៅគេនៅជំនាន់ម៉េញ ធ្វើអី? នៅគេវាយនៅសៀមរាប ឈ្មោះអីទេ។

ក៖ សម័យប៉ុលពតទេ?

ខ៖ មិនមែនសម័យប៉ុលពតទេ។

ខ៖ អីទេ! ដឹងឈ្មោះអីទេ ភ្លេចអស់ហើយ គេសម្លាប់នៅសៀមរាប។ ម្ដាយចិញ្ចឹម ជូនទៅលេង។ ហើយគេសម្លាបនៅសៀមរាប ហើយគេបិទមិនឲ្យយើងទៅ រហូត ដល់ឥឡូវទៅ។

ក៖ រហូតមកដល់ឥឡូវ! អញ្ចឹងក៏លែងបានទាក់ទងជាមួយបងប្អូនបង្កើតទៅ?

ខ៖ រហូតដល់ឥឡូវក៏លែងបានទាក់ទងជាមួយបងប្អូនបង្កើតទៅ។

ក៖ អញ្ចឹងដែរហ្ន៎?

ខ៖ ចាស៎!

ក៖ ហើយចុះអញ្ចេះ! លោកយាយមានដឹងឪពុកម្ដាយមានឈ្មោះអ្វី? គាត់កើតនៅ ឆ្នាំណាដរទេ?

ខ៖ អត់ដឹងកើតនៅឆ្នាំណាទេ។ ឪពុកឈ្មោះពេជ្រ ម្ដាយឈ្មោះពុំ។ គាត់ស្លាប់យូរ ហើយ។ អូ! អញ្ចឹងឆ្នាំហ្នឹងខ្ញុំ ៧៨ ហើយ។ គាត់ខូចយូរណាស់ហើយ ហើយយើង កូនទី ៦។

ក៖ អញ្ចឹងណា៎?

ខ៖ ចា៎ស! ស្លាប់ដាប់ឈ្លូននៅសៀមរាបហ្នឹង។

ក៖ ដាប់ឈ្លូនហ្ន៎!

ខ៖ ចា៎ស! នៅដាប់ឈ្លូន នៅសៀមរាប

ក៖ អូ! ខ្ញុំភ្លេចសួរលោកយាយ តើលោកយាយកើតនៅឆ្នាំណាដែរ?

ខ៖ វាអត់ដឹងឆ្នាំណាទេ ដឹងតែមានអាយុ ៧៨ ឆ្នាំហ្នឹង។

ក៖ ហើយចុះឪពុកម្ដាយកើតនៅសៀមរាបហ្នឹងតែម្ដង?

ខ៖ ហ្នឹងហើយ កើតនៅសៀមរាបហ្នឹងតែម្ដង។

កៈ អូខេ! ហើយអញ្ចឹងដែលលោកយាយនៅក្មេងធ្វើអីដែរ? កាលនៅជាមួយឪពុក ម្តាយចិញ្ចឹមហ្នឹងហ់?

ខៈ មានធ្វើអី! បោកគក់ខោអាវ មើលថែរក្សាផ្ទះសម្បែងក្នុងផ្ទះ។

ខៈ ឪពុកម្តាយចិញ្ចឹមជាជនជាតិចិនហ្នឹងហ់?

ខៈ ហ្នឹងហើយ!

កៈ ហើយចុះគាត់លក់អីដែរ?

ខៈ គាត់លក់សាច់ក្រណាត់ កង់ឡាន អង្ករនៅផ្ទះគាត់។

កៈ នៅសៀមរាបហ្នឹងដែរហ់?

ខៈ អត់ទេ នៅទន្លេបិទហ្នឹង។

កៈ អញ្ចឹងនៅកំពង់ចាម?

ខៈ នៅទន្លេបិទ កំពង់ចាមយើងហ្នឹងហ់។

កៈ អ៎!

ខៈ នៅជាមួយគាត់តាំងពីអាយុ ៨ ឆ្នាំ តែ ២៩ការ ទើបគាត់រៀបយើងឲ្យការ ទើប យើងតាមប្តីយើងទៅ។

កៈ អញ្ចឹង! ឪពុកម្តាយចិនអត់មានកូនសោះតែម្តង?

ខៈ មាន! កូនគេ ៦-៧ នាក់ដែរ ប៉ុន្តែដំបូងអត់ទាន់មានកូនក៏សុំយើងនៅជាមួយ។

កៈ ហើយបានមានកូនតាមក្រោយ។

ខៈ ចា់ស!

កៈ ឥឡូវហ្នឹងគាត់នៅរស់ទេ? ឪពុកម្តាយចិញ្ចឹមហ្នឹងស្លាប់ហើយហ់?

ខ៖ គាត់ស្លាប់អស់ហើយ។ ឪពុកស្លាប់នៅឆ្នាំ ១៩៩២ ហើយយាយនហ្នឹងស្លាប់នៅ ឆ្នាំ ៩០ ប៉ុន្មានទេ។ អេំ! នៅឆ្នាំ ៧៣ ហើយយាយនៅ ៩២។ នៅឆ្នាំ ៩២ គាត់ខូច។

ក៖ អញ្ចេះ! ខ្ញុំឃើញថាលោកយាយអាយុច្រើន ហើយធ្លាប់ឆ្លងកាត់សម័យអីខ្លះដែរ តាំងពីនៅក្មេង អាចរៀបរាប់បានទេ?

ខ៖ អឺ! រៀបរាប់ហ្នឹងថាពិបាកពេក សម័យដាប់យុន សម័យជប៉ុន។

ក៖ ឥឡូវយើងរៀបរាប់ពីសម័យបារាំងមុនគេ ហើយយាយអាយុប៉ុន្មានដែរ?

ខ៖ អាយុ ៨ ឆ្នាំ។

ក៖ ពេលហ្នឹងក្រមបារាំងហ្នឹងដែលឃើញបារាំងដើរតាមផ្លូវទេ?

ខ៖ ឃើញតើ បារាំងនិងជប៉ុនដើរជាមួយគ្នា។

ក៖ អញ្ជឹង ប្រហែលវាធ្វើបាបខ្មែរ?

ខ៖ វាអត់ធ្វើបាបខ្មែរអីទេ។

ក៖ ហើយគេថាទារពន្ធថ្លៃនោះ?

ខ៖ អត់ទេ! អត់មានទេ! អត់មានទារពន្ធថ្លៃអីទេ។ ស្រួលណាស់ជប៉ុននិងបារាំង។ អត់មានធ្វើបាបប្រជាជនអីទាំងអស់។

ក៖ អញ្ជឹង?

ខ៖ ខ្ញុំកើតទាន់! ខ្ញុំងើបឡើងអង្គុយមើល បារាំងអត់មានធ្វើបាបប្រជាជនយើងទេ។

ក៖ ហើយបារាំងមកមុន ហើយបន្ទាប់មកទៀតបានជប៉ុនមកក្រោយ?

ខ៖ ហ្នឹងហើយ! បារាំងនិងជប៉ុនដើរជាមួយគ្នា។

ក៖ ហើយបន្ទាប់ពីជំនាន់បារាំង ជប៉ុននឹងទៅ ចូលសម័យអីទៀតដែរ?

ខ៖ សម័យខ្មែរក្រហមហ្នឹង។

កៈ សម័យសម្តេចសិនអី។

ខៈ អាំ! ជំនាន់សម្តេច ហើយបានមកសម័យខ្មែរក្រហម។

កៈ ហើយទៅសម័យសម្តេចសប្បាយទេ?

ខៈ សម័យសម្តេចសប្បាយតើ! សប្បាយតតែអត់គាត់បានពិបាក។

កៈ អញ្ចឹងណាំ?

ខៈ ចាំស!

កៈ ហើយបន្ទាប់មកចូលក្នុងសម័យខ្មែរក្រហម?

ខៈ ចូលខ្មែរក្រហមបានពិបាកខ្លាំង។

កៈ ហើយឥឡូវកាលដែលលោកយាយនៅខ្មែរក្រហមហ្នឹង លោកយាយនៅកំពង់ ចាម?

ខៈ ហ្នំស នៅភ្នំពេញហាំ! ប្តីធ្វើទាហាន។ គេជម្លៀសទៅនៅឆ្ងាយណាស់ នៅដល់ ត្រសាង ព្រៃវែង។

កៈ អញ្ចឹងណំ! ហើយពេលខ្មែរក្រហមវាយបែក?

ខៈ មកនៅភូមិទទឹង! ធ្វើកម្មករច្រូតស្រូវ ច្រូតអីហ្នឹងណាំ ធ្វើស្រែចម្ការ។

កៈ ហើយដល់ពេលខ្មែរក្រហមចូលមកប្រាប់ថាម៉េចដែរ?

ខៈ អឺស! ចូលមកធ្វើ! ពិបាក ពិបាកមែនទែន។ ពេលខ្មែរក្រហមចូលមកពិបាក គ្រប់គ្នា។ ហៅយើងទៅវាយចោល ប៉ុន្តែយើងមិនព្រមទៅ។

កៈ អញ្ចឹង?

ខៈ ចាស់!

កៈ ហើយចុះពេលហ្នឹងយាយមានគ្រួសារដែរ?

ខៈ នៅទេ! តាមិនទាន់ខូចផង។

ក៖ អត់ទេ! អញ្ចេះ ពេលហ្នឹងរៀបការហើយណា៎?

ខ៖ រៀបការរួចហើយ មានកូនបីនាក់ហើយ។

ក៖ ហើយដល់ពេលខ្មែរក្រហមចូលមក វាប្រើឲ្យធ្វើអ្វីខ្លះ?

ខ៖ វាប្រើឲ្យច្រូតស្រូវ បាចជី ហឺយ! ពិបាក បាចទឹកស្រែសព្វគ្រប់ ហាត់ណាស់។

ក៖ ហើយទៅម្ហូបគេឲ្យបរិភោគម៉េចដែរ?

ខ៖ ស៊ីមិនគ្រប់គ្រាន់ទេ។ ស៊ីតែបបរ។

ក៖ អញ្ចឹងទៅ!

ខ៖ ចា៎ស!

ក៖ មានហើម? មិនឈឺអីទេ?

ខ៖ អត់ផង!

ក៖ អត់មានឈឺអីផង?

ខ៖ ចា៎ស! អត់មានឈឺអីផង។

ក៖ ឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់អីទេ?

ខ៖ អូស! មួយយប់ ៣៧០ នាក់យកទៅទម្លាក់ក្នុងទឹកអណ្ដូងនៅភូមិទឹង ខ្ញុំឃើញ ជាក់ស្ដែង យកទៅសម្លាប់ចោលមួយឡានអញ្ចឹងមក។ មួយថ្ងៃហ្នឹងបីទៅបួននាក់ ហើយ យប់ឡើងយក ទៅចាក់ចោលនៅភូមិទាវ នៅភូមិទឹង។

ក៖ ទម្លាក់សាកសពចូលទៅក្នុងអណ្ដូងហ្នឹងម៉ង?

ខ៖ ហ្នឹង! ចាក់ទាំងឡានតែម្ដង! ចាក់ទាំងឡានចូលអណ្ដូង។ សម្លាប់ប្រជាជន វេទនាណាស់ ។

ក៖ ហើយមានដឹងទេថា ហេតុអ្វីក៏ខ្មែរក្រហមយកទៅសម្លាប់?

ខ៖ អត់ដឹងទេ អីផង។

កៈ ប៉ុន្តែយាយឃើញ?

ខៈ ឃើញអញ្ចឹងម៉ង! យប់ឡើងវាយកទៅចាក់ចោល ហើយវាមកនិយាយថាពួកខ្ញុំ បានសម្លាប់អស់ ៣៧០ នាក់ហើយ។ វានិយាយអញ្ចឹងទៀតឲ្យយើងឮណាំ។

កៈ អឺ! មកថាទៀត។

ខៈ អឺ! យ៉ាប់ណាស់ តែខ្ញុំថាហើយ ថាមិនទៅហើយ។ ប្រើប្តីខ្ញុំឲ្យទៅជូនកូនចៅទៅ យកកាំភ្លើង យកខ្ញុំទៅសម្លាប់ចោល ប៉ុន្តែខ្ញុំអត់ទៅជាមួយ។ ងាប់រស់ចាំប្តីខ្ញុំមក សិន។ ខ្ញុំប្រកែកអញ្ចឹងមិនព្រមទៅជាមួយ។

កៈ ហើយចុះលោកយាយ មានបាត់សាច់ញាតិ កូនចៅនៅក្នុងខ្មែរក្រហមហ្នឹងទេ។

ខៈ អត់មានផង!

កៈ អញ្ចឹងអត់មានទេហ៎?

ខៈ អត់មានផង សុខសប្បាយទាំងអស់គ្នា។

កៈ ហើយចុះក្រោយទៅ ទាហានវៀតណាមគេចូលមកវាយខ្មែរក្រហមយើងហ្នឹងណាំ។

ខៈ ហ្នឹងហើយ!

កៈ ហើយពេលហ្នឹង នៅពេលវៀតណាមចូលមក ហើយថាវាពិបាក និង វាស្រួល ម៉េចដែរ?

ខៈ អត់ពិបាកទេ! មួយល្មម វាអត់មានធ្វើបាបយើងផង។

កៈ ទាហានវៀតណាមហ្នឹងហ៎?

ខៈ ចាំស!

កៈ ហើយអញ្ចេះ! បើតាមគិតមើលថាតាំងពីដឹងក្តីមក តើពេលណាដែលថាពិបាក ជាងគេ?

ខៈ ពិបាកជាងគេនៅសម័យប៉ុលពត។ ពិបាកជាងគេហើយ។ មកពួកវៀតណាម ចូលមកនៅភ្នំ អត់អីទេ។

កៈ អត់ស្វរពិបាកអីអញ្ចឹងទេ?

ខៈ អត់ស្វរពិបាកទេ។

កៈ អញ្ចេះ! ថាឥឡូវយាយនៅពេលវា ឥឡូវយើងនិយាយពីរៀនធ្វើម្ហូបធ្វើអី និង រៀនពីនរណាដែរ?

ខៈ យើងចេះខ្លួនយើង។

កៈ អត់មានរៀនពីនរណាដែរ? មើលគេ? សួរគេ?

ខៈ អត់មានទេ! អត់មានសួរពីនរណាផង។ យើងចេះខ្លួនយើង។ យើងរស់នៅជា មួយចិន។ ចិនគេបង្រៀនធ្វើម្ហូបម្ហា កាលពេលយើងមានប្ដីក៏ធ្វើម្ហូបខ្មែរឲ្យស៊ីទៅ។

កៈ អញ្ចឹងណាំ

ខៈ អញ្ចឹង!

កៈ ហើយដូចជា កាលយាយនៅជាមួយចិន តើផ្ទះធំប៉ុន្មានណាដែរ?

ខៈ ផ្ទះធំហើយគេមានលក់អង្ករ សាច់ក្រណាត់ លក់កង់ឡានអីហ្នឹង។

កៈ មិនមែនគាត់ធ្វើទេ គាត់ជួលគេ។

ខៈ អត់ទេ! ផ្ទះខ្លួនគាត់។

កៈ អញ្ចឹងណាំ!

ខៈ ចាំស!

កៈ ទៀត! ហើយអញ្ចេះ ពេលណាយាយគិតវាសប្បាយជាងគេ?

ខៈ ឥឡូវហ្នឹងសប្បយជាងគេ។

កៈ ឥឡូវហ្នឹងសប្បាយជាងគេ។

ខៈ ចាំស! វាសប្បាយជាងគេ ហើយអត់មានភិតភ័យអីទេ។ បើពេលមុនមានភិត ភ័យ។

ក៖ ដោយមិនខ្លាចគេមកសម្លាប់ ឬមានសង្គ្រាម។

ខ៖ អត់មានភិតភ័យអ្វីទេ។

ក៖ ហើយចុះកាលនៅ... បកមកក្រោយវិញ... ចុះនៅជំនាន់លន់ នល់ ជំនាន់ប៉ុល ពតអ្វីគេមានវាយគេ។ ចុះមានរត់គេចគ្រាប់អីទេ?

ខ៖ អូ! រត់គេច! ចង់រត់មិនរួច! គ្រាប់ផ្លោង គ្រាប់កាំភ្លើង រត់ចង់ងាប់ចង់រស់។ ពួន នៅបង្គន់អាចម៍ ពួននៅអណ្តូងទឹកក៏មាន។ សព្វគ្រប់ហ្នឹងហើយ។ ភិតភ័យមែនទែន  ខ្លាចស្លាប់។

ក៖ ពេលហ្នឹងនរណាបាញ់នរណា?

ខ៖ យួនបាញ់ខ្មែរ។ ខ្មែរបាញ់យួន។

ក៖ យ៉ាប់ ហើយចុះកប៉ាល់ហោះមានទម្លាក់គ្រាប់បែកអីអត់ទេ?

ខ៖ អូ! អស់ទាស់ហើយ! ទម្លាក់គ្រាប់បែក យើងគេចមិនចង់រួច។ បើយើងវាសនា បានគេចរួចនោះ បើយើងគ្មានវាសនាយើងត្រូវងាប់នឹងគ្រាប់បែកហ្នឹង។

ក៖ ហើយកាល... កាលយើងដឹងថាជំនាន់លន់ ណល់ អាមេរិចកាំងមិនមកជួយ លន់ ណល់ វាយខ្មែរក្រហមអញ្ចឹងម៉ង។ កាលនោះយាយមានឃើញកប៉ាល់បោះ អាមេរិចកាំងហោះនៅស្រុកខ្មែរទេ?

ខ៖ និយាយមិនឃើញម៉េច ឃើញកប៉ាល់បោះទម្លាក់នោះ ប៉ុន្តែអត់ឃើញមនុស្ស។

ក៖ អញ្ចឹងយើងមើលពីក្រោមដីទៅ។

ខ៖ យើងមើលពីក្រោមទៅ។

ក៖ ហើយមើលទៅ បន្ទាប់ពីទម្លាក់ទៅដល់ពេលទៅឃើញមនុស្សស្លាប់ សត្វគោ ក្របី។

ខ៖ អឺ! សត្វគោ ក្របីស្លាប់គរដូចឆ្កែឆ្មាអញ្ចឹង។ យើងឃើញនឹងភ្នែកម៉ង។

ក៖ អត់មាននរណាជួយនរណាទេ?

ខ៖ អត់មាននរណាហ៊ានជួយនរណាទេ។ គិតតែរស់រានខ្លួនឯង ងាប់តែរាងខ្លួន។

កៈ អូខេ! ហើយខ្ញុំនិយាយតទៀត ហើយចុះដល់ពេលដាច់អាពតមក តាយាយនាំ គ្នាមករស់នៅទន្លេបិទហ្នឹងវិញ?

ខៈ ហើយពេលអាពតវាយបែកមក យាយមករស់នៅទន្លេបិទហ្នឹងម៉ង រហូតដល់ សព្វថ្ងៃ។

កៈ ហើយចាប់ផ្ដើមរកស៊ីដែរ?

ខៈ ចាប់ផ្ដើមរកស៊ីធ្វើកម្មករគេទៅ។ លីសែងគេទៅ។ ហើយខ្ញុំលក់បបរ លក់នំគម លក់អីសព្វគ្រប់ដើម្បីចិញ្ចឹមជីវិតទៅ។

កៈ បាទ! អញ្ចឹងបានចិញ្ចឹមកូន។

ខៈ ចាស៎! បានចិញ្ចឹមកូន។

កៈ អញ្ចឹងកូនមានប៉ុន្មាននាក់?

ខៈ កូនទាំងអស់មាន ៦ នាក់។ ស្លាប់អស់ម្នាក់។ នៅសល់ ៥ នាក់។ ងាប់ដោយជម្ងឺ ទេ មិនមែនងាប់ដោយគេយកទៅវាយចោលនោះទេ។

កៈ មកដល់សព្វថ្ងៃ មានចៅប៉ុន្មានហើយ?

ខៈ ចៅហ៎? ចៅ ៣ នាក់។

កៈ ចៅ ៣ នាក់ហើយណា៎។

ខៈ ចៅ ៥ ទៅ ៦ នាក់ហ៎។ មិនមែនចៅ ៣ នាក់ទេ។

កៈ អញ្ចឹងអត់អីទេ លោកយាយ។ ខ្ញុំសួរមានតែប៉ុណ្ណឹងទេ។

ខៈ ចា៎ស!

កៈ ហើយជាចុងក្រោយខ្ញុំគ្រាន់តែសួរលោកយាយបន្ថែមទៀត ប្រសិនបើខ្ញុំយក សម្លេងថតហ្នឹង ក៏ដូចជារូបថតហ្នឹង យកទៅឲ្យសាកលវិទ្យាល័យដើម្បីគេដាក់នៅ លើ Internet ដើម្បីគេដាក់ផ្សាយដល់ប្រជាជនអាមេរិច ក៏ដូចជាប្រជាជនខ្មែរ មាន គេចង់ដឹង ចង់ស្ដាប់ពីប្រវត្តិយាយហ្នឹង តើយាយយល់ព្រមឲ្យគេដាក់ទេ?

ខ៖ ដាក់ទៅៗ!

ក៖ អញ្ចឹងយាយយល់ព្រមហើយណា៎?

ខ៖ ចា៎ស!

ក៖ អញ្ចឹងការថតសម្លេងហ្នឹងងគេនឹងបកប្រែ ដើម្បីឲ្យប្រជាជនដែលគាត់ចេះអង់ គ្លេស  គេបានយល់ដែលណា៎។

ខ៖ ចា៎ស!

ក៖ ហើយយើងនឹងរក្សាវាទុកនៅលើហ្នឹង។ ហើយអរគុណាច្រើនលោកយាយដែល បានផ្ញើរនេះមក។ ហើយយើងមានតែប៉ុណ្ណឹង។ Bye។